ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងបរិស្ថាន

# ថវិកាសង្ខេបឆ្នាំ ២០២៤

# ១. សេចក្តីផ្តើម

ដើម្បីជំរុញការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដំណាក់កាលទី៤ «**គណនេយ្យភាពសមិទ្ធកម្ម**» ដោយអនុវត្តចាប់ពីឆ្នាំ២០២៣ ដល់ឆ្នាំ២០២៧។ ក្រសួងបរិស្ថាន មានចក្ខុវិស័យគឺ «ធានាឱ្យបាននូវចីរភាពបរិស្ថាន និងសុក្រឹតកម្មបរិស្ថានកិច្ច ដើម្បីឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ និងលើកកម្ពស់ការអភិវឌ្ឍបៃតង»។ ក្រសួងបរិស្ថានបានដាក់ចេញនូវគោលបំណងគោលនយោបាយចម្បងៗគឺ៖

- លើកកំពស់ការវិនិយោគបៃតង តាមរយៈការកសាង ហេដ្ឋារចនាសម្ព័ន្ធថាមពលស្អាត ផលិតកម្មវៃឆ្លាត ការដឹកជញ្ជូនបៃតង ការគ្រប់គ្រងសំរាមសំណល់រឹង រាវ ប្លាស្ទិក និងសំណល់គ្រោះថ្នាក់ ការគ្រប់គ្រងគុណភាពខ្យល់ ការគ្រប់គ្រងតំបន់ការ ពារធម្មជាតិ ការពង្រីកលំហបៃតង និងគាំទ្រសេដ្ឋកិច្ចសហគមន៍មូលដ្ឋាន។
- ពង្រឹងក្របខណ្ឌគតិយុត្ត និងគោលនយោបាយពាក់ព័ន្ធនឹងបរិស្ថាន ទឹក ដី ខ្យល់ ជីវៈចម្រុះ ការប្រែប្រួលអាកាសធាតុ និងការទូតបៃតង។
- បន្តអភិវឌ្ឍស្ថាប័ន បង្កើនសមត្ថភាពមន្ត្រីជំនាញ និងចំណេះដឹងបច្ចេកទេស ទាំងការសិក្សាស្រាវជ្រាវ វិទ្យាសាស្ត្របច្ចេកវិទ្យា និងនវានុវត្តន៍លើផ្នែកបរិស្ថាន ការអភិវឌ្ឍបៃតង សន្តិសុខទឹក ជីវៈចម្រុះ និងការប្រែប្រួលអាកាសធាតុ។

ទន្ទឹមនឹងនេះ ក្រសួងបរិស្ថាន បានរៀបចំផែនការសកម្មភាពរបស់កម្មវិធី អនុកម្មវិធី និងចង្កោមសកម្មភាពរបស់អង្គភាពអនុវត្តថវិកាចំណុះកម្មវិធីនីមួយៗ ប្រកបដោយតម្លាភាពគណនេយ្យភាព ស័ក្តិសិទ្ធភាព ប្រសិទ្ធភាព និងប្រសិទ្ធផល។ ក្រសួងបរិស្ថានមានរចនាសម្ព័ន្ធកម្មវិធី និងថវិកាសង្ខេបប្រចាំឆ្នាំ ២០២៤ ដូចមានខាងក្រោម៖

# ២. រចនាសម្ព័ន្ធកម្មវិធីឆ្នាំ ២០២៤

**គោលបំណងគោលនយោបាយ៖**
**កិច្ចគាំពារបរិស្ថាន ការគ្រប់គ្រងធនធានធម្មជាតិ និងការអភិវឌ្ឍដោយចីរភាព**

- **កម្មវិធីទី១៖ កិច្ចគាំពារបរិស្ថាន**
  - អ.កទី១៖ តាមដានត្រួតពិនិត្យគុណភាពបរិស្ថាន (ទឹក-ដី-ខ្យល់) និងការគ្រប់គ្រងទឹកកខ្វក់ សំរាម សំណល់រឹងទីប្រជុំជន
  - អ.កទី២៖ ត្រួតពិនិត្យ និងអធិការកិច្ចប្រភពបំពុលបរិស្ថាន
  - អ.កទី៣៖ សេវាគាំទ្រកិច្ចគាំពារបរិស្ថាន
  - អ.កទី៤៖ សេវាគាំទ្រកិច្ចគាំពារបរិស្ថាន របស់មន្ទីរបរិស្ថាន
- **កម្មវិធីទី២៖ ការគ្រប់គ្រង និងអភិរក្សធនធានធម្មជាតិ និងការអភិវឌ្ឍសហគមន៍មូលដ្ឋាន**
  - អ.កទី១៖ គ្រប់គ្រង និងអភិរក្សតំបន់ការពារធម្មជាតិ
  - អ.កទី២៖ សេវាគាំទ្រការងារគ្រប់គ្រង និងពង្រឹងការអនុវត្តច្បាប់
  - អ.កទី៣៖ សេវាគាំទ្រការងារគ្រប់គ្រងសហគមន៍មូលដ្ឋាន
  - អ.កទី៤៖ អភិរក្សបេតិកភណ្ឌធម្មជាតិ-វប្បធម៌
  - អ.កទី៥៖ អភិវឌ្ឍទេសចរណ៍ធម្មជាតិ និងសហគមន៍មូលដ្ឋាន
  - អ.កទី៦៖ សេវាគាំទ្រការគ្រប់គ្រង និងអភិរក្សធនធានធម្មជាតិ និងការអភិវឌ្ឍសហគមន៍មូលដ្ឋាន របស់មន្ទីរបរិស្ថាន
- **កម្មវិធីទី៣៖ ការរៀបចំគោលនយោបាយ និងការអភិវឌ្ឍដោយចីរភាព**
  - អ.កទី១៖ អភិវឌ្ឍសេដ្ឋកិច្ចបៃតង និងលើកកម្ពស់ ការអនុវត្តវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា
  - អ.កទី២៖ ជំរុញការអនុវត្តឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ
  - អ.កទី៣៖ អភិរក្សជីវៈចម្រុះ និងជីវសុវត្ថិភាព
  - អ.កទី៤៖ សេវាគាំទ្រការរៀបចំគោលនយោបាយ និងការអភិវឌ្ឍដោយចីរភាព របស់មន្ទីរបរិស្ថាន
- **កម្មវិធីទី៤៖ សេវាគាំទ្រការងារបរិស្ថាន និងធនធានធម្មជាតិ**
  - អ.កទី១៖ ផ្សព្វផ្សាយបរិស្ថាន
  - អ.កទី២៖ វាយតម្លៃហេតុប៉ះពាល់បរិស្ថាន
  - អ.កទី៣៖ គ្រប់គ្រងការងាររដ្ឋបាល និងខុទ្ទកាល័យ
  - អ.កទី៤៖ គ្រប់គ្រង និងបណ្តុះបណ្តាលធនធានមនុស្ស
  - អ.កទី៥៖ គ្រប់គ្រងហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរដ្ឋ
  - អ.កទី៦៖ រៀបចំផែនការ និងលើកកម្ពស់ការងារសង្គមក្នុងវិស័យបរិស្ថាន
  - អ.កទី៧៖ ពង្រឹងអធិការកិច្ច និងសវនកម្មផ្ទៃក្នុង
  - អ.កទី៨៖ សេវាគាំទ្រការងារបរិស្ថាន និងធនធានធម្មជាតិ របស់មន្ទីរបរិស្ថាន

# ៣. ថវិកាសម្ខេបឆ្នាំ ២០២៤

| គម្រោងចំណាយថវិកាក្រសួងបរិស្ថាន តាមកម្មវិធី | ច្បាប់ហិរញ្ញវត្ថុ ឆ្នាំ ២០២៤ |
|---|---|
| **សរុបរួម** | **96,946.0** |
| សរុបរដ្ឋបាលកណ្តាល | 48,551.0 |
| សរុបមន្ទីរបរិស្ថានរាជធានី ខេត្ត | 48,395.0 |
| **១. កម្មវិធីទី១ ៖ កិច្ចគាំពារបរិស្ថាន** | **2,001.2** |
| ១.១. អនុកម្មវិធីទី១៖ ការតាមដានត្រួតពិនិត្យគុណភាពបរិស្ថាន (ទឹក-ដី-ខ្យល់) និងការគ្រប់គ្រងទឹកកខ្វក់ សំរាម សំណល់រឹងទីប្រជុំជន | 130.9 |
| ១.២. អនុកម្មវិធីទី២៖ ការត្រួតពិនិត្យ និងអធិការកិច្ចប្រភពបំពុលបរិស្ថាន | 101.5 |
| ១.៣. អនុកម្មវិធីទី៣៖ សេវាគាំទ្រកិច្ចគាំពារបរិស្ថាន | 1496.6 |
| ១.៤. អនុកម្មវិធីទី៤៖ សេវាគាំទ្រកិច្ចគាំពារបរិស្ថាន របស់មន្ទីរបរិស្ថាន | 272.2 |

# ៣. ថវិកាសខេ្មបឆ្នាំ ២០២៤ (ត)

| គម្រោងចំណាយថវិកាក្រសួងបរិស្ថាន តាមកម្មវិធី | ច្បាប់ហិរញ្ញវត្ថុ ឆ្នាំ ២០២៤ |
|---|---|
| **២. កម្មវិធីទី២ ៖ការគ្រប់គ្រង និងអភិរក្សធនធានធម្មជាតិ និងការអភិវឌ្ឍសហគមន៍មូលដ្ឋាន** | **7,236.2** |
| ២.១. អនុកម្មវិធីទី១៖ គ្រប់គ្រង និងអភិរក្សតំបន់ការពារធម្មជាតិ | 922.9 |
| ២.២. អនុកម្មវិធីទី២៖ សេវាគាំទ្រការងារគ្រប់គ្រង និងពង្រឹងការអនុវត្តច្បាប់ | 2,615.1 |
| ២.៣. អនុកម្មវិធីទី៣៖ សេវាគាំទ្រការងារគ្រប់គ្រងសហគមន៍មូលដ្ឋាន | 1,329.5 |
| ២.៤. អនុកម្មវិធីទី៤៖ អភិរក្សបេតិកភណ្ឌធម្មជាតិ-វប្បធម៌ | 252.2 |
| ២.៥. អនុកម្មវិធីទី៥៖ អភិវឌ្ឍទេសចរណ៍ធម្មជាតិ និងសហគមន៍មូលដ្ឋាន | 232.3 |
| ២.៦. អនុកម្មវិធីទី៦៖ សេវាគាំទ្រការគ្រប់គ្រង និងអភិរក្សធនធានធម្មជាតិ និងការអភិវឌ្ឍសហគមន៍មូលដ្ឋាន របស់មន្ទីរបរិស្ថាន | 1,884.2 |

# ៣. ថវិកាសខេទ្ទបឆ្នាំ ២០២៤ (ត)

| គម្រោងចំណាយថវិកាក្រសួងបរិស្ថាន តាមកម្មវិធី | ច្បាប់ហិរញ្ញវត្ថុ ឆ្នាំ ២០២៤ |
|---|---|
| **៣. កម្មវិធីទី៣ ៖ ការរៀបចំគោលនយោបាយ និងការអភិវឌ្ឍដោយចីរភាព** | **1,606.7** |
| ៣.១. អនុកម្មវិធីទី១៖ ការអភិវឌ្ឍសេដ្ឋកិច្ចបៃតង និងការលើកកម្ពស់ការអនុវត្តវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា | 1,166.9 |
| ៣.២. អនុកម្មវិធីទី២៖ ជំរុញការអនុវត្តឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ | 144.7 |
| ៣.៣. អនុកម្មវិធីទី៣៖ ការអភិរក្សជីវៈចម្រុះ និងជីវសុវត្ថិភាព | 274.4 |
| ៣.៤. អនុកម្មវិធីទី៤៖ សេវាគាំទ្រការរៀបចំគោលនយោបាយ និងការអភិវឌ្ឍដោយចីរភាព របស់មន្ទីរបរិស្ថាន | 20.7 |

# ៣. ថវិកាសខេ្ទបឆ្នាំ ២០២៤ (ត)

| គម្រោងចំណាយថវិកាក្រសួងបរិស្ថាន តាមកម្មវិធី | ច្បាប់ហិរញ្ញវត្ថុ ឆ្នាំ ២០២៤ |
|---|---|
| **៤. កម្មវិធីទី៤ ៖ សេវាគាំទ្រការងារបរិស្ថាន និងធនធានធម្មជាតិ** | **86,101.9** |
| ៤.១. អនុកម្មវិធីទី១៖ ផ្សព្វផ្សាយបរិស្ថាន | 1,567.0 |
| ៤.២. អនុកម្មវិធីទី២៖ វាយតម្លៃហេតុប៉ះពាល់បរិស្ថាន | 143.2 |
| ៤.៣. អនុកម្មវិធីទី៣៖ គ្រប់គ្រងការងាររដ្ឋបាល និងខុទ្ទកាល័យ | 376.2 |
| ៤.៤. អនុកម្មវិធីទី៤៖ គ្រប់គ្រង និងបណ្តុះបណ្តាលធនធានមនុស្ស | 24,301.2 |
| ៤.៥. អនុកម្មវិធីទី៥៖ គ្រប់គ្រងហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរដ្ឋ | 13,035.9 |
| ៤.៦. អនុកម្មវិធីទី៦៖ រៀបចំផែនការ និងលើកកម្ពស់ការងារសង្គមក្នុងវិស័យបរិស្ថាន | 268.5 |
| ៤.៧. អនុកម្មវិធីទី៧៖ ពង្រឹងអធិការកិច្ច និងសវនកម្មផ្ទៃក្នុង | 192.0 |
| ៤.៨. អនុកម្មវិធីទី៨៖ សេវាគាំទ្រការងារបរិស្ថាន និងធនធានធម្មជាតិ របស់មន្ទីរបរិស្ថាន | 46,217.9 |

# ៣. សេចក្ដីសន្និដ្ឋាន

ដើម្បីសម្រេចគោលបំណងគោលនយោបាយរបស់ក្រសួង ក្នុងការរួមចំណែកអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាល ក្រសួងបរិស្ថាន នឹងអនុវត្តថវិកាកម្មវិធីឱ្យស្របទៅនឹងយុទ្ធសាស្ត្រចក្រាវិស័យបរិស្ថាន ២០២៣-២០២៨ ដោយផ្ដោតសំខាន់ទៅលើចក្ខុវិស័យដូចតទៅ៖

- **ភាពស្អាត** ៖ សំដៅការគ្រប់គ្រងសំរាម សំណល់រឹង រាវ និងសំណល់ប្រកបដោយគ្រោះថ្នាក់ប្រកបដោយសុវត្ថិភាពបរិស្ថាន ជាពិសេសការដាក់ចេញនូវយុទ្ធនាការកាត់បន្ថយថង់ប្លាស្ទិក ក្រោមប្រធានបទ «ថ្ងៃនេះខ្ញុំមិនប្រើថង់ប្លាស្ទិកទេ»
- **ភាពបៃតង** ៖ ប្រែក្លាយប្រទេសកម្ពុជា ឱ្យមានផ្ទៃបៃតង ៦០% នៅឆ្នាំ២០៥០ តាមរយៈការពង្រីកចលនាដាំដើមឈើ ការជំរុញការគ្រប់គ្រងតំបន់ការពារធម្មជាតិ និងលើកម្ពស់ជីវភាពសហគមន៍មូលដ្ឋាន
- **ចីរភាព** ៖ សំដៅលើអនុលោមភាព ស្របតាមយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ របស់រាជរដ្ឋាភិបាលនៃនីតិកាលទី៧ រដ្ឋសភា ការពង្រីកកិច្ចសហប្រតិបត្តិការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ អង្គការដៃគូជាមួយក្រសួងបរិស្ថាន និងពង្រឹងការសម្របសម្រួល។